## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលរាជធានីភ្នំពេញ**
លេខ : ០០៣/២១ សណន

# សេចក្តីណែនាំ
## ស្តីពី
## ការរឹតបន្តឹងការអនុវត្តវិធានការចត្តាឡីស័កនៅតាមទីតាំងឯកជន ដែលជាប់ពាក់ព័ន្ធ "ព្រឹត្តិការណ៍សហគមន៍ ២០-កុម្ភៈ" ក្នុងរាជធានីភ្នំពេញ

**យោង៖** -លិខិតលេខ ១២៧ សជណ.មយ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
-សេក្តីណែនាំលេខ ២១៣ សខល ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០ របស់ក្រសួងសុខាភិបាល
-សេចក្តីប្រកាសព័ត៌មានលេខ ១៣ បទ.សជណ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២១ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

ក្រោយការផ្ទុះឡើងជាលើកទី៣ នៃជំងឺកូវីដ-១៩ ក្នុង **"ព្រឹត្តិការណ៍សហគមន៍ ២០-កុម្ភៈ" រដ្ឋបាលរាជធានីភ្នំពេញ** បានប្រើប្រាស់កម្លាំងសរុប មធ្យោបាយសរុប និងវិធានការសរុប ជាពិសេសបានបង្កើតគណៈបញ្ជាការស្រាល និងបង្កើនកម្លាំងយាមប្រចាំការ **២៤/២៤ម៉ោង** តាមបណ្តាមន្ទីរពេទ្យព្យាបាល និងគោលដៅចត្តាឡីស័កទាំងរដ្ឋ និងឯកជន ដែលជាប់ពាក់ព័ន្ធព្រឹត្តិការណ៍នេះ ហើយត្រូវបានកំណត់ថាជាទីតាំងចត្តាឡីស័ក។

ជាមួយគ្នានេះ ដើម្បីជំរុញ និងគាំទ្រដល់ការអនុវត្តវិធានការចត្តាឡីស័ក ឱ្យកាន់តែមានប្រសិទ្ធភាព ផ្អែកតាមគោលការណ៍អនុញ្ញាតដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា រដ្ឋបាលរាជធានីភ្នំពេញ និង ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** បានបើកកិច្ចប្រជុំរួមគ្នា និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រង QR Code **"ទប់ស្កាត់កូវីដ Stop Covid"** តាមបណ្តាអង្គភាពរដ្ឋ និងអាជីវកម្មដ្ឋានក្នុងរាជធានីភ្នំពេញ ដែលនេះគឺជាផ្នែកមួយចូលរួមបង្ការ-ទប់ស្កាត់ការរីករាលដាលសកលជំងឺកូវីដ-១៩ ស្របតាមការណែនាំរបស់ក្រសួងសុខាភិបាល។

តាមរយៈយន្តការខាងលើនេះ **រដ្ឋបាលរាជធានីភ្នំពេញ** ពិនិត្យឃើញថា បណ្តាទីតាំងឯកជនដែលជាប់ពាក់ព័ន្ធព្រឹត្តិការណ៍ ហើយត្រូវបានកំណត់ថាជាទីតាំងចត្តាឡីស័ក ក៏ដូចជាប្រជាពលរដ្ឋខ្មែរ និងជនបរទេសដែលត្រូវដាក់ឱ្យធ្វើចត្តាឡីស័កតាមបណ្តាគោលដៅឯកជនទាំងនោះ ភាគច្រើនលើសលុបបានអនុវត្តយ៉ាងត្រឹមត្រូវតាមវិធានចត្តាឡីស័ក **ប៉ុន្តែ ក៏នៅមានក្រុមមនុស្សពាក់ព័ន្ធមួយចំនួនតូច បានល្មើសនឹងវិធាននេះ ដោយអនុវត្តមិនបានពេញលេញ** ដូចជា គេចវេះមិនព្រមសហការជាមួយអាជ្ញាធរមូលដ្ឋាន មិនស្តាប់តាមការណែនាំរបស់មន្ត្រីសុខាភិបាល ធ្វេសប្រហែស និងមានបុគ្គលខ្លះបានលួចចេញមកខាងក្រៅក្នុងអំឡុងពេលធ្វើចត្តាឡីស័ក ដែលអាចបង្កហានិភ័យយ៉ាងធ្ងន់ធ្ងរដល់សហគមន៍ និងសុខភាពសាធារណៈទាំងមូល។



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

**ចំពោះមុខ** ដើម្បីរឹតបន្តឹងការអនុវត្តវិធានការចត្តាឡីស័កនៅតាមទីតាំងឯកជន ផ្តោតសំខាន់លើលំនៅឋានឯកជន អគារស្នាក់នៅរួម និងអាជីវកម្មដ្ឋានទាំងឡាយ ដែលជាប់ពាក់ព័ន្ធ **"ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ"** និងត្រូវបានកំណត់ថាជាទីតាំងចត្តាឡីស័កនោះ **រដ្ឋបាលរាជធានីភ្នំពេញ** សូមធ្វើការក្រើនរំលឹក និងណែនាំដូចខាងក្រោម៖

១. ប្រជាពលរដ្ឋខ្មែរ និងជនបរទេស ដែលត្រូវដាក់ឱ្យធ្វើចត្តាឡីស័កតាមគោលដៅឯកជនទាំងឡាយ ត្រូវនៅក្នុងផ្ទះ ឬ បន្ទប់ដាច់ដោយឡែកគ្រប់ពេលវេលាទាំងអស់ ក្នុងរយៈពេល **១៤ ថ្ងៃ គឺហាមដាច់ខាតដើរចេញក្រៅផ្ទះ ឬ បន្ទប់ ឬ ទីកន្លែងដែលខ្លួនត្រូវធ្វើចត្តាឡីស័ក**។

២. អនុលោមតាមអនុក្រឹត្យលេខ **២៧ អនក្រ.បក** ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីវិធានការចត្តាឡីស័កដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បានកំណត់ថា **"បុគ្គលដែលគេចវេះពីការធ្វើចត្តាឡីស័ក ឬ បុគ្គលដែលគេចចេញពីទីកន្លែងធ្វើចត្តាឡីស័ក នឹងត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី ១លាន ដល់ ៥លានរៀល ព្រមទាំងត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន"**។

៣. ប្រធានក្រុមសន្តិសុខការពារគោលដៅចត្តាឡីស័ក ក្រុមគ្រូពេទ្យប្រចាំការ អាជ្ញាធរមូលដ្ឋាន និងគ្រប់ភាគីពាក់ព័ន្ធ ត្រូវបង្កើនស្មារតីយកចិត្តទុកដាក់ គ្រប់គ្រង ឃ្លាំមើល ណែនាំ និងមានចំណាត់ការឱ្យបានទាន់ពេលវេលា ដើម្បីធានាថាក្រុមបុគ្គលទាំងឡាយ ដែលកំពុងធ្វើចត្តាឡីស័កស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ពិតជាបានអនុវត្តយ៉ាងខ្ជាប់ខ្ជួនតាមវិធានចត្តាឡីស័ក និងការណែនាំរបស់ក្រសួងសុខាភិបាល។

៤. ម្ចាស់អាជីវកម្មដ្ឋានទាំងអស់ ត្រូវដាក់កម្លាំងបុគ្គលិកប្រចាំការ សម្រាប់ត្រួតពិនិត្យដល់បុគ្គលទាំងឡាយដែលចូលមកក្នុងទីតាំងរបស់ខ្លួន **ត្រូវស្កេន QR Code ឱ្យបានត្រឹមត្រូវ** ដើម្បីបានដឹងពីស្ថានភាពពាក់ព័ន្ធនឹងជំងឺកូវីដ-១៩ របស់បុគ្គលទាំងនោះ តាមរយៈការបង្ហាញពណ៌លើអេក្រង់ទូរសព្ទក្រោយពេលស្កេនរួច (ពណ៌បៃតង លឿង ឬ ពណ៌ក្រហម)។ ក្នុងករណីស្កេនឃើញ ពណ៌លឿងបញ្ជាក់ថាបុគ្គលនោះកំពុងស្ថិតក្នុងការធ្វើចត្តាឡីស័ក និង ពណ៌ក្រហមបញ្ជាក់ថាបុគ្គលនោះមានជំងឺកូវីដ-១៩ **ដូច្នេះ** ម្ចាស់អាជីវកម្មដ្ឋានត្រូវរាយការណ៍ជាបន្ទាន់មកអាជ្ញាធរមានសមត្ថកិច្ច ដើម្បីមានវិធានការ។ ផ្ទុយទៅវិញ ប្រសិនបើម្ចាស់អាជីវកម្មដ្ឋានណាមួយមិនអនុវត្តតាមវិធានការខាងលើនេះ **រដ្ឋបាលរាជធានីភ្នំពេញ** នឹងចាត់វិធានការច្បាប់បន្ថែមចំពោះបុគ្គល និងទីតាំងដែលមិនសហការ ដោយត្រូវដកហូតអាជ្ញាប័ណ្ណ និងបិទអាជីវកម្មទាំងស្រុង។

ទទួលបានសេចក្តីណែនាំនេះ នាយករដ្ឋបាលសាលារាជធានីភ្នំពេញ អភិបាល នៃគណៈអភិបាលខណ្ឌទាំង១៤ ស្នងការនគរបាលរាជធានីភ្នំពេញ មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ ប្រធានមន្ទីរសុខាភិបាលរាជធានីភ្នំពេញ ប្រធានមន្ទីរ-អង្គភាពជំនាញពាក់ព័ន្ធ និងម្ចាស់ទីតាំងចត្តាឡីស័កឯកជន ព្រមទាំងក្រុមបុគ្គលដែលកំពុងធ្វើចត្តាឡីស័កទាំងឡាយ ត្រូវអនុវត្តឱ្យខាងតែបានតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ប្រកបដោយប្រសិទ្ធភាព និងស្មារតីទទួលខុសត្រូវខ្ពស់៕

ថ្ងៃអង្គារ ១១ រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០២១

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសុខាភិបាល
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
  *"ដើម្បីជូនជ្រាបជាព័ត៌មាន"*
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
- រដ្ឋបាលខណ្ឌទាំង១៤
- មន្ទីរ-អង្គភាពពាក់ព័ន្ធ
  *"ដើម្បីមុខការ"*
- គ្រប់ប្រព័ន្ធឃោសនា
  *"ដើម្បីផ្សព្វផ្សាយ"*
- **ឯកសារ-កាលប្បវត្តិ**



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh